**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងអភិវឌ្ឍន៍ជនបទ**

លេខៈ ១១៤៧/ក.អ.ជ/១៩

ថ្ងៃចន្ទ ៦រោច ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១៩

# របាយការណ៍

## វឌ្ឍនភាពការងារប្រចាំឆមាសទី ១ ឆ្នាំ ២០១៩ របស់ក្រសួងអភិវឌ្ឍន៍ជនបទ

## I. សេចក្តីផ្តើម

ក្នុងកិច្ចដំណើរការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល និងក្រោយការកែសម្រួលគោលនយោបាយ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជនបទឆ្នាំ ២០១៩-២០២៣ មក តំបន់ជនបទបានចាប់ផ្តើមប្រែផ្លាស់មុខមាត់ថ្មីមួយកម្រិតថែមទៀត បើយើងពិនិត្យទៅមើលស្ថានភាពជីវភាពរស់នៅប្រចាំថ្ងៃ ប្រជាពលរដ្ឋមានជីវភាពធូរជារជាងមុនទាំងសម្ភារៈប្រើប្រាស់ប្រចាំថ្ងៃ ដូចជាទូរស័ព្ទដៃ ទូរទស្សន៍ មធ្យោបាយធ្វើដំណើរឯកជនរួមមាន ម៉ូតូ រថយន្ត តូច ធំ គ្រឿងចក្រធុនស្រាលបម្រើឲ្យវិស័យកសិកម្ម និងសេវាកម្ម ។ ផ្នែកទិដ្ឋភាពសេវាសាធារណៈ ផ្លូវជនបទទាំងផ្លូវក្រួសក្រហម ផ្លូវកៅស៊ូ និងផ្លូវបេតុង បាននិងកំពុងតភ្ជាប់គ្នាជាបណ្តាញ ( Network ) គ្រប់ភូមិ ឃុំ ស្រុក ខេត្តរហូតដល់តំបន់ដាច់ស្រយាល និងតាមព្រំដែនបង្កភាពងាយស្រួលដល់ការធ្វើដំណើរ ការតាំងទីលំនៅឋានថ្មី និងការដឹកជញ្ជូនផ្លូវគោក (Logistic) សម្រាប់បម្រើឲ្យវិស័យសេដ្ឋកិច្ច ។ ផ្នែកសេវាសុខភាពសាធារណៈជនបទត្រូវបានពង្រឹងគុណភាពតាមរយៈការផ្តល់សេវាទឹកស្អាត សេវាអនាម័យ ការអប់រំពីរបៀបរស់ស្អាតនៅទាន់សម័យ (Lifestyle) ក្នុងកម្រិតសហគមន៍ជនបទ ដោយបញ្ឈប់ជាបណ្តើរៗការបន្ទោរបង់ពាសវាលពាសកាល ការទុកដាក់សម្រាមបានត្រឹមត្រូវ ហូបស្អាត ផឹកស្អាត និងរស់នៅស្អាត ។ ការលើកកម្ពស់ជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋតាមគ្រួសារក្នុងសហគមន៍ជនបទនៅតែជាបញ្ហាចម្បងដែលក្រសួងកំពុងផ្តោតយកចិត្តទុកដាក់តាមរយៈបង្កើតកម្មវិធីបំណិនជីវិត បណ្តុះបណ្តាលជំនាញអាជីពដល់ប្រជាពលរដ្ឋជនបទ ដើម្បីប្រែក្លាយពីប្រជាជនធម្មតាឲ្យជាពលរដ្ឋដែលមានអាជីពមួយច្បាស់លាស់ក្នុងជីវិតដែលអាចធានា ទ្រទ្រង់ និងបង្កើនស្ថេរភាពប្រាក់ចំណូលប្រចាំថ្ងៃសមស្របនឹងការវិវត្តន៍របស់សង្គមបច្ចេកវិទ្យានាពេលបច្ចុប្បន្ន នឹងទៅអនាគត ។ សកម្មភាពទាំងអស់ដូចបានរៀបរាប់ខាងលើ ត្រូវបានក្រសួងកំពុងប្រែក្លាយជាផែនការសកម្មភាពអនុវត្តជាក់ស្តែង ដែលបានរំលេចចេញក្នុងរបាយការណ៍ឆមាសទី១ ឆ្នាំ២០១៩ ដូចខាងក្រោមៈ

## II. អំពីការងារគ្រប់គ្រងរបស់ក្រសួង

### ១. ការងាររដ្ឋបាល និងបុគ្គលិក

ដោយគិតត្រឹមដំណាច់ឆមាសទី ១ ឆ្នាំ ២០១៩ មន្ត្រីរាជការក្របខណ្ឌសរុបមានចំនួន

១ ៨០៤ នាក់ ។ ក្រសួងបានទទួលលិខិតចូលចំនួន ៩៣៩ ច្បាប់ លិខិតចេញក្រៅក្រសួងចំនួន ៩០៨ ច្បាប់ ចុះលេខប្រកាស និងសេចក្ដីសម្រេចនានា ចំនួន ១៧៦ ច្បាប់ និងចុះលេខលិខិតបេសកកម្ម ចំនួន ១ ៤៦១ ច្បាប់ ។

២. ក្រុមការងារចុះមូលដ្ឋានតាមដានការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤

ក្នុងឆមាសទី ១ ឆ្នាំ ២០១៩ លេខាធិការដ្ឋានទទួលបានសំណើ សំណូមពររបស់ប្រជាពលរដ្ឋនៅមូលដ្ឋានតាមរយៈវេទិកាសាធារណៈថ្នាក់ជាតិសរុប ចំនួន ៧៥ ករណី ដែលក្នុងនោះបានដោះស្រាយជូនប្រជាពលរដ្ឋបានចំនួន ១១ ករណី ។

៣. ការងារផ្គត់ផ្គង់ និងហិរញ្ញវត្ថុ

ក្នុងឆមាសទី ១ ឆ្នាំ ២០១៩ ក្រសួងបានអនុវត្តចំណាយ ធៀបនឹងច្បាប់ហិរញ្ញវត្ថុសម្រាប់ឆ្នាំ ២០១៩ សម្រេចៈ

- ចំណាយចរន្តអនុវត្តបានចំនួន ១២ ៧០៩ ២៣៣ ៧៤០ រៀល ស្មើនឹង ៩,៧០% នៃច្បាប់ថវិកា
- ចំណាយមូលធនអនុវត្តបានចំនួន ២៨ ១០៩ ១៦៦ ០០០ រៀល ស្មើនឹង ១៤,៧៩% នៃច្បាប់ថវិកា ។

៤. ការងារផែនការ និងសហប្រតិបត្តិការអន្តរជាតិ

- ចូលរួមប្រជុំរៀបចំសិន្និបាតក្រសួងដឹកនាំដោយ **ឯកឧត្តម សួស គន់** រដ្ឋលេខាធិការប្រចាំការ នៅទីស្ដីការក្រសួង
- ចូលរួមកិច្ចប្រជុំការងារក្រៅអង្គភាព ចំនួន ០៧ លើក
- ជួបពិភាក្សាជាមួយអង្គការក្រៅរដ្ឋាភិបាល នៅទីស្ដីការក្រសួង ចំនួន ០៥ លើក
- ចុះពិនិត្យមើលការអនុវត្តផែនការឆ្នាំ ២០១៨ និងផែនការថវិកាឆ្នាំ ២០១៩ នៅខេត្តក្រចេះ ស្ទឹងត្រែង និងខេត្តរតនគិរី
- ចូលរួមកិច្ចប្រជុំពិភាក្សាលើការងារកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ស្ដីពីការរៀបចំផែនការសកម្មភាពដំណាក់កាលទី៣ ឆ្នាំ ២០១៩ នៅទីស្ដីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចំនួន ០៦ លើក
- ចុះណែនាំពីការធ្វើអង្កេតទិន្នន័យអភិវឌ្ឍន៍ជនបទ និងពង្រឹងស្ថិតិ នៅខេត្តក្រចេះ សៀមរាប មណ្ឌលគិរី ពោធិ៍សាត់ និងរតនគិរី ស្ទឹងត្រែង បាត់ដំបង ព្រះវិហារ និងឧត្តរមានជ័យ
- ចុះណែនាំលើការរៀបចំឯកសារផែនការយុទ្ធសាស្ត្រឆ្នាំ ២០២០-២០២២ ណែនាំការរៀបចំផែនការកម្មវិធីឆ្នាំ ២០២០ និងពិនិត្យកែសម្រួល ការរៀបចំឯកសារផែនការយុទ្ធសាស្ត្រឆ្នាំ ២០២០-២០២២ នៅខេត្តសៀមរាប មណ្ឌលគិរី ស្ទឹងត្រែង បន្ទាយមានជ័យ រតនគិរី ក្រចេះ ត្បូងឃ្មុំ កំពង់ធំ ពោធិ៍សាត់ ប៉ៃលិន បាត់ដំបង និងខេត្តព្រះវិហារ
- ចូលរួមកិច្ចប្រជុំស្ដីពីការងារកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងចូលរួមសិក្ខាសាលាចំនួន ០៤ លើក នៅទីស្ដីការក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងខេត្តកែប

- ចូលរួមកិច្ចប្រជុំការងារផែនការ និងស្ថិតិ និងវគ្គបណ្តុះបណ្តាលជាមួយក្រសួងផែនការ ចំនួន ០៧ លើក នៅទីស្តីការក្រសួងផែនការ និងខេត្តសៀមរាប
- រៀបចំ ចងក្រងសៀវភៅផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជនបទ ឆ្នាំ២០១៩-២០២៣
- ដឹកនាំរៀបចំសិក្ខាសាលាពិនិត្យ និងកែសម្រួលឈ្មោះកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាព ក្នុងផែនការយុទ្ធសាស្ត្រថវិកាប្រចាំឆ្នាំ ២០២០-២០២២ នៅខេត្តសៀមរាប បានចំនួន ០២ លើក
- ដឹកនាំរៀបចំសិក្ខាសាលាស្តីពីកម្មវិធីវិនិយោគសាធារណៈបីឆ្នាំរំកិល ឆ្នាំ២០២០-២០២២ របស់ក្រសួងអភិវឌ្ឍន៍ជនបទ តាមអនឡាញ នៅទីស្តីការក្រសួង
- ចូលរួមប្រជុំពិនិត្យឡើងវិញរបាយការណ៍ ស្តីពីការអនុវត្តគម្រោងមេគង្គឡានឆាងដែលរៀបចំឡើងដោយក្រសួងការបរទេស និងភាគីចិនមកពីនាយកដ្ឋានហិរញ្ញវត្ថុនៃក្រសួងការបរទេសចិន និងកុងស៊ុលចិនប្រចាំនៅកម្ពុជា នៅទីស្តីការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ចុះតាមដានការអនុវត្តថវិកាកម្មវិធីនៅខេត្តចំនួន ១០ គឺ ខេត្តត្បូងឃ្មុំ កំពង់ចាម កែប កំពត កំពង់សោម កោះកុង បាត់ដំបង ពោធិ៍សាត់ កំពង់ធំ និងខេត្តសៀមរាប
- ធ្វើបច្ចុប្បន្នភាពប្រព័ន្ធគ្រប់គ្រងមូលដ្ឋានទិន្នន័យផ្លូវជនបទ ប្រព័ន្ធគ្រប់គ្រងទិន្នន័យមន្ត្រីរាជការ និងគេហទំព័រក្រសួងអភិវឌ្ឍន៍ជនបទ
- ដឹកនាំរៀបចំសិក្ខាសាលាស្តីពី "ការគ្រប់គ្រងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងគោលនយោបាយអភិវឌ្ឍន៍វិស័យទូរគមនាគមន៍ និងព័ត៌មាន របស់ក្រសួងអភិវឌ្ឍន៍ជនបទ" នៅទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ
- ដឹកនាំរៀបចំសិក្ខាសាលា ស្តីពីការបូកសរុបលទ្ធផលការងារត្រីមាសទី១ ឆ្នាំ២០១៩ និងការពង្រឹងកិច្ចសហប្រតិបត្តិការរវាងក្រសួងអភិវឌ្ឍន៍ជនបទ និងអង្គការមិនមែនរដ្ឋាភិបាល
- ដឹកនាំរៀបចំសិក្ខាសាលាស្តីពី ការផ្លាស់ប្តូរបទពិសោធន៍លើការរៀបចំផែនការបន្សាំ ការប្រែប្រួលអាកាសធាតុនៅក្នុងវិស័យអភិវឌ្ឍន៍ជនបទ
- បានចុះពិនិត្យការងារជាក់ស្តែងរបស់អង្គការក្រៅរដ្ឋាភិបាលនៅក្នុង ខេត្តមណ្ឌលគិរី ក្រចេះ (០២លើក) រតនគិរី ព្រះវិហារ ស្ទឹងត្រែង សៀមរាប បន្ទាយមានជ័យ ពោធិ៍សាត់ បាត់ដំបង និងខេត្តត្បូងឃ្មុំ (០២លើក)
- បានចុះកិច្ចព្រមព្រៀងសហប្រតិបត្តិការរវាងក្រសួងអភិវឌ្ឍជនបទ និងអង្គការមិនមែនរដ្ឋាភិបាលបានចំនួន ១១ លិខិត
- បានផ្តល់សំណើសុំហត្ថលេខាលើកិច្ចព្រមព្រៀងសហប្រតិបត្តិការរវាង ក្រសួងការបរទេស និងសហប្រតិបត្តិអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាលចំនួន ០២លិខិត
- បានផ្តល់សំណើសុំធ្វើវិសោធនកម្មលើកិច្ចព្រមព្រៀងគម្រោង រវាងក្រសួងអភិវឌ្ឍន៍ជនបទ និងអង្គការមិនមែនរដ្ឋាភិបាលបានចំនួន ០១ លិខិត
- បានផ្តល់លិខិតអន្តរាគមន៍ដើម្បីនាំចូលរថយន្ត បានចំនួន ០៣ លិខិត

- បានផ្តល់សំណើសុំអន្តរាគមន៍ដើម្បីចុះបញ្ជីសុំស្លាកលេខ ONG សម្រាប់ទោចក្រយានយន្ត និង រថយន្ត ចំនួន ០៤ លិខិត
- បានផ្តល់សំណើសុំនាំចូលកង់ចំនួន ១៩៤ គ្រឿង ទំងន់ ៨ ៣៤១,២៥ គីឡូក្រាម របស់អង្គការមិនមែនរដ្ឋាភិបាល ចំនួន ០១ លិខិត

៥. ការងារកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

ដើម្បីរួមចំណែកពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ និងពង្រឹងការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយក្នុងដំណាក់កាលទី៣នៃកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្រសួងអភិវឌ្ឍន៍ជនបទសម្រេចបានលទ្ធផលដូចខាងក្រោម៖

- កែសម្រួលសមាសភាពក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- ក្នុងឆមាសទី១ ឆ្នាំ២០១៩ **ឯកឧត្តម សួស គង់** រដ្ឋលេខាធិការប្រចាំការ និងជាប្រធានក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក្រសួងអភិវឌ្ឍន៍ជនបទបានដឹកនាំសិក្ខាសាលា និងវគ្គបណ្តុះបណ្តាលចំនួន ៣ ដោយប្រើប្រាស់ថវិកាកំណែទម្រង់ (EU) ៖
  - ទី១៖ រៀបចំសិក្ខាសាលាពិគ្រោះយោបល់ស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២០-២០២២ របស់ក្រសួងអភិវឌ្ឍន៍ជនបទ នៅសណ្ឋាគារអង្គរខេមរា ខេត្តសៀមរាបដោយមានសិក្ខាកាមចូលរួម ១១០ នាក់ មកពីថ្នាក់មន្ទីរ និងថ្នាក់កណ្តាល
  - ទី២៖ បើកវគ្គបណ្តុះបណ្តាលកម្មវិធី FMIS សម្រាប់ការអនុវត្តឆ្នាំ២០២០ នៅខេត្តបាត់ដំបងដោយមានសិក្ខាកាមចូលរួម ៦០ នាក់ មកពីថ្នាក់មន្ទីរ និងថ្នាក់កណ្តាល
  - ទី៣៖ បើកវគ្គបណ្តុះបណ្តាលស្តីពីការកសាងសមត្ថភាពផែនការថវិកានៅខេត្តកែប ដោយមានសមាជិកចូលរួមចំនួន ៥០ នាក់ ។
- ចូលរួមកិច្ចប្រជុំប្រកាសស្តីពីការដាក់ឲ្យដំណើរការប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យាហិរញ្ញវត្ថុ (FMIS) សាកល្បងសម្រាប់១០ ក្រសួង និងមន្ទីរហិរញ្ញវត្ថុទាំង ២៥ រាជធានី ខេត្ត
- បញ្ចប់ការកែសម្រួលផែនការសកម្មភាពដំណាក់កាលទី៣ (MAP3) ឆ្នាំ ២០១៩
- បញ្ចប់ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២០-២០២២ ដោយបានបោះពុម្ពជាសៀវភៅសម្រាប់ផ្សព្វផ្សាយ និងបានបង្ហោះក្នុងវេបសាយក្រសួង
- ធ្វើបច្ចុប្បន្នភាពផែនការថវិកាកម្មវិធីឆ្នាំ២០២០ ស្របតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ NSDP 2019-2023 និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ពិសេសស្របតាមកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី៣ (MAP3)
- ប្រជុំរៀបចំផែនការលទ្ធកម្មក្រសួង
- ចុះតាមដានការអនុវត្តថវិកាកម្មវិធីនៅខេត្តចំនួន ១០ គឺ ខេត្តត្បូងឃ្មុំ កំពង់ចាម កែប កំពត កំពង់សោម កោះកុង បាត់ដំបង ពោធិ៍សាត់ កំពង់ធំ និងខេត្តសៀមរាប
- រៀបចំដាក់ឲ្យដំណើរការប្រព័ន្ធ FMIS របស់ក្រសួង
- រៀបចំរបាយការណ៍ចំណូល ចំណាយ និងរបាយការណ៍វឌ្ឍនភាពស្តីពីការអនុវត្ត MAP3 ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- កែលម្អការរៀបចំកម្មវិធីចំណាយប្រចាំត្រីមាសឲ្យកាន់ តែមានសុក្រឹត្យភាព
- ពង្រឹងការរៀបចំកិច្ចប្រតិបត្តិការ គណនេយ្យ និងធ្វើការផ្ទៀងផ្ទាត់ជាមួយគណនី
- ត្រួតពិនិត្យ រៀបចំប្រព័ន្ធ និងយន្តការនៃការចុះបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋទាំងថ្នាក់កណ្តាល និងអង្គភាពថ្នាក់ក្រោមជាតិ
- តាមដានវឌ្ឍនភាពនៃការអនុវត្តការធ្វើរបាយការណ៍តាមទម្រង់របាយការណ៍ថ្មី
- ផ្សព្វផ្សាយផែនការលទ្ធកម្ម ប្រចាំឆ្នាំ និងការប្រគល់កិច្ចសន្យា
- ផ្សព្វផ្សាយរបាយការណ៍វឌ្ឍនភាពប្រចាំខែ ប្រចាំត្រីមាស និងប្រចាំឆ្នាំ លើគេហទំព័រ
- តាមដានការអនុវត្តអនុសាសន៍របស់សវនករដែលបានលើកឡើង ។

៦. ការងារអធិការកិច្ច និងសវនកម្ម

- ចុះធ្វើអធិការកិច្ចលើការងារគ្រប់គ្រងចំណូល-ចំណាយ និងការប្រើប្រាស់ថវិការបស់រដ្ឋការិយបរិច្ឆេទ២០១៨ នៅមន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពត កែប ព្រះសីហនុ កោះកុង កំពង់ចាម ត្បូងឃ្មុំ តាកែវ ព្រៃវែង និងស្វាយរៀង
- បានជួបប្រជុំជាមួយគណៈប្រតិភូក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ដែលដឹកនាំដោយ **ឯកឧត្តម ចាន់ កុលបុត្រ** អនុរដ្ឋលេខាធិការ ក្នុងគោលបំណងដើម្បីទំនាក់ទំនង និងក្តាប់សភាពការណ៍នៃការអនុវត្តតួនាទី និងភារកិច្ចរបស់អគ្គាធិការដ្ឋានតាមបណ្តាក្រសួង ស្ថាប័ន
- ចូលរួមកិច្ចប្រជុំក្រុមជនបង្គោលប្រឆាំងអំពើពុករលួយរបស់ក្រសួងអភិវឌ្ឍន៍ជនបទ នៅទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ
- ចុះធ្វើសវនកម្មលើការគ្រប់គ្រងរដ្ឋបាល ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ថវិកាតាមកម្មវិធី ឆ្នាំ ២០១៨ - ២០១៩ និងចុះពិនិត្យជាក់ស្តែងការងារសាងសង់ ជួសជុលអណ្តូងទឹក និងសាងសង់បង្គន់អនាម័យដោយប្រើប្រាស់ថវិការដ្ឋ នៅមន្ទីរអភិវឌ្ឍន៍ជនបទខេត្តចំនួន ១២ រួមមាន ព្រៃវែង ស្វាយរៀង ប៉ៃលិន បាត់ដំបង រតនគិរី មណ្ឌលគិរី កោះកុង ព្រះសីហនុ ឧត្តរមានជ័យ សៀមរាប កំពង់ចាម និងត្បូងឃ្មុំ ។

## III. **សកម្មភាពការងារជំនាញ**

១. ការងារអភិវឌ្ឍន៍ផ្លូវជនបទ

- គម្រោងស្តាបនា កែលម្អផ្លូវ និងសំណង់សិល្បការ្យ ឆ្នាំ២០១៩ មាន ៨២ គម្រោងកំពុងដំណើរការការដ្ឋានបានចំនួន ៦៩គម្រោង លទ្ធផលគិតជាមធ្យម ៤៣.៧២ %
- ការងារថែទាំផ្លូវលក្ខណៈខួប ឆ្នាំ២០១៩ មាន ចំនួន ២៨ គម្រោង ស្មើនឹង ៦៣ ខ្សែ ដំណើរការការដ្ឋានលទ្ធផលគិតជាមធ្យម ៥៥.១១ %
- ការងារថែទាំផ្លូវលក្ខណៈប្រចាំ ឆ្នាំ២០១៩ មានចំនួន ៤០ គម្រោង ស្មើនឹង ៣៦៩ ខ្សែ ដំណើរការការដ្ឋានលទ្ធផលគិតជាមធ្យម ១៧.៤៨ %

- ចូលរួមជាមួយគណៈកម្មការអន្តរក្រសួងចុះត្រួតពិនិត្យ និងវាយតម្លៃបញ្ចប់សុពលភាព បានចំនួន ៣៣ គម្រោង ក្នុងនោះមាន ៖
  - ផ្លូវកៅស៊ូប្រវែង ២៨,៨៥ គ.ម
  - ផ្លូវបេតុងប្រវែង ៧,៧៤២ គ.ម
  - ផ្លូវក្រាលក្រួសក្រហមប្រវែង ១៨០,៥២ គ.ម
  - សំណង់លូមូល លូប្រអប់ ២៥១ កន្លែង
  - ស្ពានបេតុងចំនួន ១២ កន្លែង ប្រវែង ៤០៨ ម
  - ផ្លាកឈ្មោះគម្រោងផ្លូវ ចំនួន ២៩ កន្លែង ។

## ២. ការងារផ្គត់ផ្គង់ទឹកជនបទ

- ចុះខួងអណ្តូងជូនកងពលតូចទ័ពពិសេសឆ័ត្រយោង ៩១១ និងគ្រួសារទ័ពចំនួន ០២ អណ្តូង នៅខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ
- ខួងអណ្តូង ចំនួន ០១ អណ្តូង ជូនសាលាសង្កាត់ពន្សាំង ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ
- កំពុងបន្តការងារខួងអណ្តូងនៅសាលានគរបាលជាតិមិត្តភាពកម្ពុជា-វៀតណាម នៅឃុំត្រែងត្រយឹង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ
- ចុះខួងអណ្តូង បានចំនួន ០៣ អណ្តូង និងកំពុងបន្តខួងអណ្តូងទី ០៤ នៅ ក្រុងតាខ្មៅ ខេត្តកណ្តាល
- បានចូលរួមប្រជុំផ្សព្វផ្សាយគម្រោងឧបត្ថម្ភធនដល់គ្រួសារក្រីក្រ គ្មានលទ្ធភាពតបណ្តាញទឹកស្អាត នៅខេត្តព្រៃវែង និងកណ្តាល ។

## ៣. ការងារថែទាំសុខភាព និងអនាម័យជនបទ

- បានសាងសង់បង្គន់អនាម័យចាក់ទឹកតាមផ្ទះឯកជន ចំនួន ៧២១ ខ្នងផ្ទះ នៅខេត្តរតនគិរី ពោធិ៍សាត់ កំពង់ចាម និងឧត្តរមានជ័យ
- បានសាងសង់បង្គន់អនាម័យចាក់ផេះតាមផ្ទះឯកជន ចំនួន ២៤៣ ខ្នងផ្ទះ នៅខេត្តពោធិ៍សាត់
- បានចុះបំផុសការសាងសង់បង្គន់អនាម័យដល់សហគមន៍តាមភូមិ គោលដៅ នៅក្នុងខេត្តកែប កោះកុង ក្រចេះ ប៉ៃលិន ឧត្តរមានជ័យ និងសៀមរាប បាន៩៨៥គ្រួសារ
- បានចុះធ្វើការវាយតម្លៃ និងផ្សព្វផ្សាយគោលការណ៍ណែនាំការលើកកម្ពស់អនាម័យសហគមន៍ នៅខេត្តប៉ៃលិន ព្រះសីហនុ និងឧត្តរមានជ័យ ដែលមានអ្នកចូលរួមសរុប១៦០នាក់ និងស្ត្រី ៦៤នាក់
- បានរៀបចំវគ្គបណ្តុះបណ្តាលគ្រូបង្គោលសម្រាប់អនុវត្តកម្មវិធី CLTS ដោយមានសមាសភាពចូលរួមមកពីខេត្តគោលដៅចំនួន ០៦ ខេត្ត គឺ ស្វាយរៀង កំពង់ស្ពឺ តាកែវ ក្រចេះ រតនគិរី និងព្រះវិហារ សរុបអ្នកចូលរួមចំនួន ៦៧ នាក់ស្រី ២៥ នាក់។
- បានចុះត្រួតពិនិត្យតាមដាន និងបំផុសការលើកកម្ពស់អនាម័យ នៅសង្កាត់ទួលសង្កែI សង្កាត់ទួលសង្កែII និងសង្កាត់ស្វាយប៉ាក ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ

- បានចុះធ្វើការវាយតម្លៃ និងផ្សព្វផ្សាយគោលការណ៍ណែនាំសហគមន៍ដឹកនាំអនុវត្តអនាម័យ នៅខេត្ត ចំនួន ១១ រួមមានខេត្តកោះកុង ក្រចេះ កំពង់ចាម ព្រះសីហនុ សៀមរាប ឧត្តរមានជ័យ កំពង់ឆ្នាំង កំពង់ស្ពឺ ត្បូងឃ្មុំ ស្វាយរៀង និងកែប
- បានផ្តល់វគ្គបណ្តុះបណ្តាលបច្ចេកទេសអំពីការពិនិត្យផ្ទៀងផ្ទាត់ផ្ទៃក្នុង ភូមិ ODF ទៅដល់មន្ត្រីអង្គការ iDE
- បានចូលរួមពិនិត្យផ្ទៀងផ្ទាត់ភូមិ ODF នៅខេត្តបាត់ដំបង និងខេត្តពោធិ៍សាត់ ចំនួន ១៧ ភូមិ ក្នុងឃុំ ជាលទ្ធផលភូមិចំនួន ១៦ជាប់ជាភូមិ ODF ។

## ៤. ការងារអភិវឌ្ឍន៍សហគមន៍

- ចុះពិនិត្យវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ នៅខេត្តកំពង់ស្ពឺ ត្បូងឃ្មុំ កំពត កំពង់ចាម តាកែវ ព្រះវិហារ កំពង់ឆ្នាំង ឧត្តរមានជ័យ បន្ទាយមានជ័យ ព្រៃវែង និងបាត់ដំបង
- រៀបចំសិក្ខាសាលាផ្លាស់ប្តូរបទពិសោធន៍ការងារពង្រឹងសមត្ថភាពគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ នៅខេត្តរតនគិរីដែលអញ្ជើញចូលរួមពីមន្ត្រីមកពីមន្ទីរអភិវឌ្ឍន៍ជនបទរាជធានី ខេត្ត ចំនួន ១៦ ខេត្ត អង្គការពាក់ព័ន្ធ ក្រុមប្រឹក្សាស្រុក ខេត្ត សរុបចំនួន ១០៤ នាក់ ស្រី ២១ នាក់
- ចុះតាមដានការធ្វើបច្ចុប្បន្នភាព និងពិភាក្សាការងារពង្រឹងគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ នៅខេត្តតាកែវ ស្វាយរៀង និងព្រៃវែង
- ចុះពិនិត្យ និងតាមដានការអនុវត្តគម្រោងលើកកំពស់សន្តិសុខស្បៀងជាលក្ខណៈគ្រួសារ នៅខេត្តព្រះសីហនុ កំពង់ឆ្នាំង និងកែប
- ចុះពិនិត្យវគ្គបណ្តុះបណ្តាលស្តីពី ការត្រៀមបង្ការ និងកាត់បន្ថយគ្រោះភ័យក្នុងសហគមន៍ នៅខេត្តមណ្ឌលគិរី និងកំពង់ធំ
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តកំពង់ស្ពឺ បានបើកវគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ក្នុងវគ្គទី ១ ឆមាសទី១ ឆ្នាំ ២០១៩ ចំនួន ០៤ មុខជំនាញ មានសិក្ខាកាមចូលរួមចំនួន ១២១ នាក់ ស្រី ៥៥ នាក់
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តតាកែវ បានចុះផ្សព្វផ្សាយជ្រើសរើសសិក្ខាកាមចូលរៀន និងបានបើកវគ្គបណ្តុះបណ្តាលកសិកម្ម ចំនួន ១២ វគ្គ មានសិក្ខាកាមចូលរួមចំនួន ២៤០ នាក់ ស្រី ១០៩ នាក់ ។

## ៥. ការងារបណ្តុះបណ្តាល

- មន្ត្រីចូលរួមសិក្ខាសាលាក្នុងប្រទេស ចំនួន ១ ១៦៤ នាក់ ក្នុងនោះស្រីចំនួន ២១៦ នាក់
- មន្ត្រីចូលរួមវគ្គបណ្តុះបណ្តាលក្នុងប្រទេស ចំនួន ៥៣០ នាក់ ក្នុងនោះស្រីចំនួន ៦៥ នាក់
- មន្ត្រីចូលរួមវគ្គបណ្តុះបណ្តាលក្រៅប្រទេស ចំនួន ១១ នាក់ ក្នុងនោះស្រីចំនួន ០២ នាក់
- បានផ្សព្វផ្សាយសេចក្តីជូនដំណឹងដល់មន្ត្រីរាជការទាំងពីរភេទរបស់ក្រសួងអភិវឌ្ឍន៍ជនបទ ទាក់ទងនឹងអាហារូបករណ៍ និងព័ត៌មានផ្សេងៗបានចំនួន ១៥ លើក

- បានរៀបចំវគ្គបណ្តុះបណ្តាល និងសិក្ខាសាលា ចំនួន ០៤ លើក នៅទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ ដោយមានសិក្ខាកាមចូលរួមសរុប ២៣៩ នាក់ ស្រីចំនួន ៣៦ នាក់
- បានរៀបចំឯកសារដាក់ជូនថ្នាក់ដឹកនាំក្រសួងពិនិត្យ និងសម្រេចក្នុងការបញ្ជូនមន្ត្រីចូលរួមវគ្គបណ្តុះបណ្តាលក្នុង និងក្រៅប្រទេសបានចំនួន ១៩ លើក
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តព្រៃវែង បានបើកវគ្គបណ្តុះបណ្តាលជំនាញមូលដ្ឋានដែលមានសិក្ខាកាមចូលរៀនសរុបចំនួន ៩៦ នាក់ ស្រី ៧២ នាក់ លើ ០៤ មុខជំនាញ
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តស្វាយរៀង បានបានបើកវគ្គបណ្តុះបណ្តាលជំនាញមូលដ្ឋានដែលមានសិក្ខាកាមចូលរៀនសរុបចំនួន ១៥០ នាក់ ស្រី ៦៥ នាក់ លើមុខជំនាញចំនួន ០៦ មុខជំនាញ
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តកំពង់ចាម បានបានបើកវគ្គបណ្តុះបណ្តាលជំនាញមូលដ្ឋានដែលមានសិក្ខាកាមចូលរៀនសរុបចំនួន ១៥១ នាក់ ស្រី ៨០ នាក់ លើមុខជំនាញចំនួន ០៣ មុខជំនាញ
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តបាត់ដំបង បានបានបើកវគ្គបណ្តុះបណ្តាលជំនាញមូលដ្ឋានដែលមានសិក្ខាកាមចូលរៀនសរុបចំនួន ១៨៣ នាក់ ស្រី ៨២ នាក់ លើមុខជំនាញចំនួន ០៨ មុខជំនាញ
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តពោធិ៍សាត់ បានបានបើកវគ្គបណ្តុះបណ្តាលជំនាញមូលដ្ឋានដែលមានសិក្ខាកាមចូលរៀនសរុបចំនួន ១២០ នាក់ ស្រី ៨៣ នាក់ លើមុខជំនាញចំនួន ០៤ មុខជំនាញ
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តកំពត បានបានបើកវគ្គបណ្តុះបណ្តាលជំនាញមូលដ្ឋានដែលមានសិក្ខាកាមចូលរៀនសរុបចំនួន ៧៩ នាក់ ស្រី ៤០ នាក់ លើមុខជំនាញចំនួន ០៣ មុខជំនាញ
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តកំពង់ធំ បានបើកវគ្គជួសជុល និងថែទាំអណ្តូងស្នប់ចំនួន ០១ វគ្គ មានសិក្ខាកាមសរុបចំនួន ៣០ នាក់ ស្រី ១៩ នាក់
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តបន្ទាយមានជ័យ បានបើកវគ្គភាសាអង់គ្លេស ចំនួន ០២ វគ្គដែលមានសិក្ខាកាមចូលរៀនសរុបចំនួន ៥០ នាក់ ស្រី ២០ នាក់
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តសៀមរាប បានបានបើកវគ្គបណ្តុះបណ្តាលជំនាញមូលដ្ឋានដែលមានសិក្ខាកាមចូលរៀនសរុបចំនួន ៦០ នាក់ ស្រី ៤១ នាក់ លើមុខជំនាញចំនួន ០២ មុខជំនាញ ។

## ៦. ការងារអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ

- គិតត្រឹមថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ ២០១៩ ប្រតិបត្តិករឥណទានជនបទដែលមន្ទីរអភិវឌ្ឍន៍ជនបទខេត្តអនុវត្តផ្ទាល់ និងសហការជាមួយដៃគូ និងសកម្មភាពការងារឥណទានដែលអនុវត្តដោយសហគមន៍សន្សំប្រាក់ បានផ្តល់ឥណទានសរុបចំនួន ៤ ១៦២ ៧៥៧ ៨៣៥ រៀល (បួនពាន់មួយរយហុកសិបពីរលានប្រាំពីររយហាសិបប្រាំពីរពាន់ប្រាំបីរយសាមសិប

ប្រាំរៀល) ស្មើនឹង ១ ០៥៩ ៩១៥,៤២ ដុល្លារអាមេរិក (មួយលានហាសិបប្រាំបួនពាន់ប្រាំបួនរយដប់ប្រាំដុល្លារនិងសែសិបពីរសេន) (១USD=៤០០០រៀល) មានអ្នកខ្ចីសរុបចំនួន ៤ ៣៥៤ នាក់នៅភូមិគោលដៅចំនួន ១៩៥ ភូមិ ៧១ឃុំ ៣២ស្រុក ក្នុងខេត្តគោលដៅចំនួន ១៥

- ចុះធ្វើអធិការកិច្ចលើគម្រោងឥណទានក្រសួងអភិវឌ្ឍន៍ជនបទខេត្តកំពង់ចាម និងត្បូងឃ្មុំ
- ចូលរួមកិច្ចប្រជុំផ្សព្វផ្សាយ ស្តីពីការរៀបចំគម្រោងសម្រាប់ស្នើសុំជំនួយហិរញ្ញប្បទានឥតសំណងពីរដ្ឋាភិបាលចិន ក្រោមក្របខណ្ឌកិច្ចសហប្រតិបត្តិការមេគង្គ ឡានឆាង ឆ្នាំ២០១៩
- បានធ្វើការបូកសរុប និងសម្របសម្រួលគាំទ្រផ្នែកបច្ចេកទេសគ្រប់គ្រងធនាគារស្រូវដល់សហគមន៍ដែលមានស្រូវសរុបចំនួន ១០ ០០០ គ.ក ស្ថិតនៅដៃសមាជិកកំពុងប្រើប្រាស់សរុបចំនួន ៨៦ នាក់ ស្រី ៦៤ នាក់
- បានចុះត្រួតពិនិត្យ និងតាមដានការអនុវត្តគម្រោងសិប្បកម្មផលិតសាប៊ូ ចំនួន ០១ វគ្គ ០៣ លើក នៅខេត្តកំពង់ធំ មានសិក្ខាកាមចូលរួមសរុប ៦០ នាក់
- បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីការធ្វើសិប្បកម្មផលិតសាប៊ូលាងចានចំនួន ០៦ វគ្គ នៅខេត្តកំពង់ធំ និងខេត្តត្បូងឃ្មុំ មានសិក្ខាកាមចូលរួមសរុបចំនួន ១២០ នាក់
- បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយ ស្តីពីគំនិតផ្តួចផ្តើម និងការគ្រប់គ្រងអាជីវកម្មខ្នាតតូចនៅខេត្តប៉ៃលិន មានសិក្ខាកាមចូលរួមសរុប ៤៦ នាក់
- បានរៀបចំសិក្ខាសាលាស្តីពីការរៀបចំគម្រោងសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចជនបទ និងស្វែងយល់ការងារទីផ្សារ នៅខេត្តប៉ៃលិន និងបាត់ដំបង ។

### ៧. ការងារគ្រប់គ្រង និងអភិវឌ្ឍន៍ជនជាតិដើមភាគតិច

- ចូលរួមកិច្ចប្រជុំ ស្តីពីការពិនិត្យឡើងវិញលើការងារកំណត់អត្តសញ្ញាណសហគមន៍ជនជាតិភាគតិចជង ចំនួន ០៥ សហគមន៍ នៅតំបន់អារ៉ែង ខេត្តកោះកុង ដែលមានភាពយឺតយ៉ាវនៅថ្នាក់ក្រោមជាតិ
- បានចូលរួមកិច្ចប្រជុំ ស្តីពីការបង្កើតក្រុមការងារដឹកនាំ និងអនុវត្តគោលនយោបាយជាតិស្តីពីការអភិវឌ្ឍន៍ជនជាតិភាគតិច ជាមួយអង្គការដៃគូ (CIPO, CIYA)
- ចូលរួមកិច្ចប្រជុំពេញអង្គ របស់សហគមន៍ដើម្បីពិនិត្យ និងអនុម័តលើខ្លឹមសារព្រាងបទបញ្ជាផ្ទៃក្នុង ស្តីពី ការគ្រប់គ្រងដីធ្លី និងធនធានធម្មជាតិ សហគមន៍ជនជាតិដើមភាគតិចព្រៅ និងលុន នៅខេត្តរតនគិរី
- ចូលរួមកិច្ចប្រជុំពេញអង្គ ពិនិត្យ និងអនុម័តលើសេចក្តីព្រាងលក្ខន្តិកៈ និងគណៈកម្មាធិការសហគមន៍ជនជាតិដើមភាគតិច កាវែត និងទំពួន ចំនួន ០៤ សហគមន៍ នៅខេត្តស្ទឹងត្រែង និងរតនគិរី
- ចូលរួមធ្វើបទបង្ហាញអំពីគោលនយោបាយអភិវឌ្ឍន៍ជនជាតិដើមភាគតិច សារាចរណែនាំ ស្តីពីស្វ័យអត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច និងដំណើរការរៀបចំបទបញ្ជាផ្ទៃក្នុង

នៃការប្រើប្រាស់ និងគ្រប់គ្រងដីសហគមន៍ជនជាតិដើមភាគតិច ដល់អាជ្ញាធរថ្នាក់ក្រោមជាតិ និងសហគមន៍ នៅស្រុករវៀង ខេត្តព្រះវិហារ

- ចូលរួមកិច្ចប្រជុំពិភាក្សាការងារជនជាតិដើមភាគតិច ជាមួយអង្គការដៃគូ អំពីគម្រោង និងទិសដៅបន្ត
- ទំនាក់ទំនងជាមួយអង្គការដៃគូ និងក្រសួងពាក់ព័ន្ធ ដើម្បីរៀបចំធ្វើផែនការអភិវឌ្ឍន៍ជនជាតិដើមភាគតិចតាមបណ្តាខេត្តទាំង ១៥ ។

## ៨. ការងារយេនឌ័រ

- បានចូលរួមកិច្ចប្រជុំពិភាក្សា ស្តីពី លក្ខន្តិកៈរបស់បណ្តាញសហគ្រិនស្ត្រីកម្ពុជា
- បានរៀបចំសិក្ខាសាលាស្តីពីការ ផ្សព្វផ្សាយទស្សនៈយេនឌ័រ អនុសញ្ញាស៊ីដ (CEDAW ) និងអនុសាសន៍របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** នៅមន្ទីរអភិវឌ្ឍន៍ជនបទខេត្តតាកែវ និងកំពត
- បានចូលក្រាបថ្វាយបង្គំគាល់ **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង** និង **សម្តេចព្រះមហាក្សត្រីព្រះវររាជមាតាជាតិខ្មែរ** ក្នុងឱកាសអបអរសាទរខួបលើកទី១០៨ ទិវាអន្តរជាតិនារី ៨ មីនា ឆ្នាំ២០១៩
- ចូលរួមសិក្ខាសាលាពិគ្រោះយោបល់ ស្តីពីយេនឌ័រ និងកាបន្សាំនឹងការបម្រែបម្រួលអាកាសធាតុ
- រៀបចំកម្មវិធីអបអរសាទរខួបលើកទី ១០៨ ទិវាអន្តរជាតិនារី ៨ មីនា ឆ្នាំ ២០១៩ លើប្រធានបទ "លើកកម្ពស់សមភាពយេនឌ័រ និងការគាំពារសង្គម ដើម្បីអភិវឌ្ឍន៍ធនធានមនុស្ស" នៅទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ
- ចូលរួមក្នុងពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់ស្តីពី កិច្ចប្រតិបត្តិការ ផ្តល់សេវាការពារក្តីដល់ស្ត្រី និងក្មេងស្ត្រីក្រីក្រដែលរងគ្រោះដោយអំពើហិង្សា និងការអប់រំច្បាប់
- រៀបចំសិក្ខាសាលាស្តីពីការលើកកម្ពស់សមភាពយេនឌ័រ និងការបង្កើនភាពអង់អាចក្លាហានផ្នែកសេដ្ឋកិច្ចដល់ស្ត្រីនៅតាមសហគមន៍ នៅខេត្តកំពង់ចាម និងត្បូងឃ្មុំ ។
- ចូលរួមសិក្ខាសាលាអន្តរវិស័យថ្នាក់ជាតិ ស្តីពីការលើកម្ពស់សុវត្ថិភាពស្ត្រី និងការបញ្ជ្រាបយេនឌ័រ ទៅនឹងការប្រែប្រួលអាកាសធាតុ នៅសណ្ឋាគារសាន់វេ
- ចូលរួមកិច្ចប្រជុំប្រចាំត្រីមាស របស់គណៈកម្មាធិការដឹកនាំ និងសម្របសម្រួលការងារយេនឌ័រ និងការប្រែប្រួលអាកាសធាតុនៃក្រសួងកិច្ចការនារី ។

## ៩. ការងារប្រយុទ្ធនឹងជំងឺអេដស៍

- បានរៀបចំប្រជុំក្រុមការងារដើម្បីរៀបចំផែនការសម្រាប់អនុវត្តការងារ ឆ្នាំ២០១៩ នៅទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ

- ចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសប្រចាំខែរបស់អាជ្ញាធរជាតិប្រយុទ្ធ នឹងជំងឺអេដស៍ ក្រោមអធិបតីភាពរបស់ **ឯកឧត្តម វេជ្ជ.តែង គន្ធី** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ចំនួន ០៣ លើក នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
- រៀបចំសិក្ខាសាលា ស្តីពីការពង្រឹងសមត្ថភាពរបស់មន្ត្រីរាជការគណៈកម្មាធិការការប្រយុទ្ធនឹងជំងឺអេដស៍ និងការរៀបចំផែនការសម្រាប់អនុវត្តន៍ឆ្នាំបន្ទាប់ នៅទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ ក្រោមអធិបតីភាព **លោកជំទាវ ម៉ាត់ ម៉ារ៉ា** ប្រធានគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួងអភិវឌ្ឍន៍ជនបទ
- រៀបចំសិក្ខាសាលាផ្សព្វផ្សាយ ស្តីពី លើកកម្ពស់ការយល់ដឹងពីជំងឺអេដស៍ កាមរោគ និងសុខភាពបន្តពូជ ដល់ប្រជាពលរដ្ឋនៅខេត្តកំពង់ឆ្នាំង មានសមាសភាពចូលរួមសរុបចំនួន ៩០ នាក់ ស្ត្រី ៦៤ នាក់។

១០. ក្រុមការងារបច្ចេកទេសវិមជ្ឈការ និងវិសហមជ្ឈការ

- ប្រជុំក្រុមការងារវិមជ្ឈការ និងវិសហមជ្ឈការក្រសួងអភិវឌ្ឍន៍ជនបទ ដើម្បីពិភាក្សាលើមុងារចំនួន ០៣ ដែលត្រូវផ្ទេរជូនទៅថ្នាក់ក្រោមជាតិ ដែលរួមមាន មុខងារថែទាំជួសជុលសំណង់ទឹកស្អាតជនបទ មុខងារផ្តល់សេវាអនាម័យរួមមានការសាងសង់បង្គន់អនាម័យសាធារណៈ និងមុខងារថែទាំផ្លូវ
- ប្រធានក្រុមការងារវិមជ្ឈការ និងវិសហមជ្ឈការក្រសួងអភិវឌ្ឍន៍ជនបទ បានដឹកនាំមន្ត្រីបច្ចេកទេសជាន់ខ្ពស់របស់ក្រសួង ចូលរួមកិច្ចប្រជុំដើម្បីកំណត់មុខងារជាក់លាក់សម្រាប់ផ្ទេរឲ្យទៅរដ្ឋបាលក្រុង ស្រុក នៅលេខាធិការដ្ឋាន គ.ជ.អ.ប
- ចូលរួមក្នុង សិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីព្រាងអនុក្រឹត្យ ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅរបស់រដ្ឋបាលក្រុង ស្រុក
- កំពុងបន្តរៀបចំមុខងារទាំង ០៣ ដែលត្រូវផ្ទេរដល់រដ្ឋបាលថ្នាក់ក្រោមជាតិ។

## IV. ការអនុវត្តគម្រោង និងកម្មវិធីសហប្រតិបត្តិការផ្សេងៗ

១. គម្រោងកែលម្អផ្លូវជនបទ ជំហាន ២

អនុវត្តក្នុងខេត្តគោលដៅចំនួន១០ គឺ ខេត្តត្បូងឃ្មុំ កំពង់ចាម តាកែវ កំពង់ស្ពឺ កំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប និងកំពង់ធំ គិតត្រឹមដំណាច់ឆមាសទី ១ នេះ គម្រោងសម្រេចបាន ៖

- ខេត្តត្បូងឃ្មុំ : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៩ខ្សែ មានប្រវែងសរុប ១៩៣,៩ គ.ម សម្រេចបាន ១០០%
- ខេត្តតាកែវ : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៩ខ្សែ មានប្រវែងសរុប ១០៤,០៨គ.ម សម្រេចបាន ៤៤,៤៤%
- ខេត្តកំពង់ស្ពឺ : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ១០ខ្សែ មានប្រវែងសរុប ១៦១,៦០គ.ម សម្រេចបាន ៥៨,៥៦%
- ខេត្តកំពង់ឆ្នាំង : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៩ខ្សែ មានប្រវែងសរុប ១២៦,៣០គ.ម សម្រេចបាន ៤៦,៣៨%

- ខេត្តកំពង់ធំ : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៤ខ្សែប្រវែង ១១៣,៤០គ.ម សម្រេចបាន ៤៨,៩៤%
- ខេត្តសៀមរាប : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៦ខ្សែ មានប្រវែងសរុប ១២៦,២០ គ.ម សម្រេចបាន ៣១,៤៥%
- ខេត្តពោធិ៍សាត់ : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ១០ខ្សែ មានប្រវែងសរុប ១២៥,៥០គ.ម សម្រេចបាន ៩៦,៩៣%
- ខេត្តបាត់ដំបង : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៨ខ្សែ មានប្រវែងសរុប ១០១,២០គ.ម សម្រេចបាន ៩៦,៨៨%
- ខេត្តបន្ទាយមានជ័យ :បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៥ខ្សែ មានប្រវែងសរុប ៩០,៧០ គ.ម សម្រេចបាន ៩២,៨១%
- ខេត្តកំពង់ចាម : បាន និងកំពុងដំណើរការសាងសង់ផ្លូវក្រាលបេតុងចំនួន ០៦ខ្សែ មានប្រវែងសរុប ៥០គ.ម សម្រេចបាន ១០០% ។

**២. គម្រោងកែលម្អហេដ្ឋារចនាសម្ព័ន្ធជនបទដំហានទី ៦**

គម្រោងកែលម្អហេដ្ឋារចនាសម្ព័ន្ធជនបទដំហានទី ៦ ជាគម្រោងសហហិរញ្ញប្បទានឥតសំណងរវាងរដ្ឋាភិបាលសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ តាមរយៈធនាគារ KfW និងរាជរដ្ឋាភិបាលកម្ពុជា អនុវត្តនៅខេត្តបន្ទាយមានជ័យ។ គិតត្រឹមដំណាច់ឆមាសទី១ នេះ គម្រោងសម្រេចបាន ៖

- ស្រុកមង្គលបុរី : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៣ខ្សែ មានប្រវែងសរុប ២៧,២០ គ.ម សម្រេចបាន ១៨,៩០%
- ស្រុកអូរជ្រៅ : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០១ខ្សែ មានប្រវែងសរុប ២០ គ.ម សម្រេចបាន ២៣% ។
-

**៣. គម្រោងសាច់ប្រាក់ពលកម្មសម្រាប់អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធជនបទ និងការគាំទ្រកសិករ**

គម្រោងសាច់ប្រាក់ពលកម្ម សម្រាប់អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធជនបទ និងការគាំទ្រកសិករ មានរយៈពេល ០៣ ឆ្នាំ គិតចាប់ពី ឆ្នាំ២០១៧ ដល់ឆ្នាំ២០១៩ និងផ្តោតលើការស្តារ និងកែលំអផ្លូវជនបទ ដោយត្រូវអនុវត្តជា ២ ដំហាន ដែលអនុវត្តក្នុងខេត្តគោលដៅចំនួន ១២ គឺ ខេត្តកណ្តាល តាកែវ ស្វាយរៀង កំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប កំពង់ធំ កំពង់ស្ពឺ ព្រៃវែង និងឧត្តរមានជ័យ ។ គិតត្រឹមដំណាច់ ឆមាសទី ១ នេះ គម្រោងដែលបានស្នើសុំក្រាលក្រួសក្រហមចំនួន ១៤១គម្រោង បាននិងកំពុងអនុវត្តការងារ បានចំនួន ១២៨គម្រោង ប្រវែងសរុប ៥៤៥ ១៧៧ម៉ែត្រ ដោយឡែកសម្រាប់ដំហាន ២ គម្រោង បាននិងកំពុងអនុវត្តចំនួន ១៦០ គម្រោង ប្រវែង ១៦១ ៤០៦ម៉ែត្រ ។

៤. គម្រោងផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទទី ២

- សាងសង់បង្គន់តាមខ្នងផ្ទះ ចំនួន ១ ២០៥ បង្គន់ ក្នុងស្រុកបាកាន និងស្រុកកណ្ដៀង ខេត្តពោធិ៍សាត់
- សាងសង់បង្គន់សាធារណៈ ១៧ កន្លែង និងអាងត្រងទឹកភ្លៀង ១៧ កន្លែង នៅខេត្តកំពង់ឆ្នាំង សម្រេចបាន ១០០%
- សាងសង់ថ្នាលហាលលាមកមានដំបូលថ្លាពេញ (Model3) និងថ្នាលហាលលាមកមានភ្ជាប់ឡជីវឧស្ម័ន (Model1) នៅខេត្តបាត់ដំបង សម្រេចបាន ១០០%
- សាងសង់ស្រះសហគមន៍ចំនួន ០១ កន្លែង សម្រេចបាន ១០០% នៅខេត្តពោធិ៍សាត់
- សាងសង់អណ្ដូងស្នប់ ចំនួន ០៥ អណ្ដូង សម្រេច ១០០% នៅខេត្តពោធិ៍សាត់
- បានផ្ដល់ពាងតាមខ្នងផ្ទះ ចំនួន ៤ ៧៥៩ ពាង នៅខេត្តពោធិ៍សាត់
- ចូលរួមសហការជាមួយមជ្ឈមណ្ឌលបណ្ដុះបណ្ដាលវិជ្ជាជីវមូលដ្ឋាន ស្ដីពីការថែទាំ និងការជួសជុលអណ្ដូងស្នប់ (O&M) របស់ក្រុមប្រឹក្សាឃុំ គណៈកម្មាធិការអភិវឌ្ឍន៍ភូមិ ក្រុមអ្នកប្រើប្រាស់ទឹក និងជនបង្គោលអនាម័យថ្នាក់ភូមិ នៅខេត្តបន្ទាយមានជ័យ ។

៥. លទ្ធផលសម្រេចបានពីកិច្ចសហការជាមួយអង្គការមិនមែនរដ្ឋាភិបាល

ក្នុងឆមាសទី១ ឆ្នាំ២០១៩ មានអង្គការមិនមែនរដ្ឋាភិបាលចំនួន ៥៣ កំពុងសហការជាមួយក្រសួងអភិវឌ្ឍន៍ជនបទ ។ គិតត្រឹមចុងខែមិថុនានេះ ក្រសួងបានទទួលរបាយការណ៍តែ ២៨ អង្គការប៉ុណ្ណោះដែលបានផ្ញើមកក្រសួងអភិវឌ្ឍន៍ជនបទ ។ លទ្ធផលដែលអង្គការសម្រេចបានក្នុងវិស័យអភិវឌ្ឍន៍ជនបទចម្បុះរួមមាន ៖

- សាងសង់ផ្លូវបាន ១០ ខ្សែ ស្ពានចំនួន ០៩ កន្លែង ស្រះទឹកចំនួន ៤០ ស្រះ
- សាងសង់អណ្ដូងបាន ៤៣១ អណ្ដូង
- សាងសង់បង្គន់អនាម័យបានចំនួន ១១ ៥៦៣ បង្គន់
- សាងសង់កន្លែងលាងសម្អាតដៃតាមសាលាបានចំនួន ៤ ១៥៤ កន្លែង
- សាងសង់ផ្ទះជូនប្រជាជនបានចំនួន ៤០ ខ្នង
- សាងសង់ទំនប់បង្ហៀរបានចំនួន ១៣ កន្លែង
- សាងសង់ឡដុតសម្រាមបានចំនួន ១៣៦ ឡ
- សាងសង់ធុងទឹកចម្រោះបានចំនួន ១០ ៥៥១ ធុង អាងត្រងទឹកភ្លៀងបានចំនួន ២១៥ អាង
- ចែកម៉ាស៊ីនបូមទឹកបានចំនួន ០៩ គ្រឿង ផ្ដល់ពាងជូនប្រជាជនបានចំនួន ២៧៦ ពាង
- បង្កើតផ្សារចល័តជនបទបានចំនួន ១២ កន្លែង បង្កើតសួនដាំបន្លែបានចំនួន ២៨ កន្លែង
- សាងសង់ស្ថានីយ៍ទឹកស្អាតបានចំនួន ២៧២ ស្ថានីយ៍
- ផ្ដល់ និងជុសជុលប្រព័ន្ធសូឡាជូនប្រជាជនបានចំនួន ១៥០ ផ្ទាំង
- បើកវគ្គបណ្ដុះបណ្ដាលស្ដីពីសុខភាពអនាម័យជូនប្រជាជនបានចំនួន ១ ០៦៩ វគ្គ ។

## V. **សេចក្តីសន្និដ្ឋាន**

លទ្ធផលក្នុងឆមាសទី១ ខាងលើបានបង្ហាញពីសមិទ្ធផលយ៉ាងច្រើនដែលរាជរដ្ឋាភិបាលខិតខំប្រឹងប្រែងជំនះគ្រប់ឧបសគ្គដើម្បីធានាឲ្យបានភាពសុខដុមរម្យនារបស់ប្រជាពលរដ្ឋ ពិសេសប្រជាពលរដ្ឋដែលកំពុងរស់នៅក្នុងសហគមន៍ជនបទ។ ជារួមទាំងផ្នែកហេដ្ឋារចនាសម្ព័ន្ធរូបវន្តទាំងផ្នែកសេវាសម្រាប់សាធារណៈជននៅជនបទត្រូវបានកែលម្អកាន់តែប្រសើរឡើងពីមួយថ្ងៃទៅមួយថ្ងៃ ចំណែកសេវាអប់រំសុខភាព អនាម័យ បរិស្ថានរស់នៅស្អាត ត្រូវបានរាជរដ្ឋាភិបាលយកចិត្តទុកដាក់ពង្រឹងគុណភាពនិងផ្តល់គុណតម្លៃនៃជីវិតរបស់ប្រជាពលរដ្ឋកាន់តែប្រសើរឡើង ឆ្លើយតបនឹងគោលដៅនៃការអភិវឌ្ឍប្រកបដោយចីរភាពឆ្នាំ២០៣០ របស់អង្គការសហប្រជាជាតិ ក៏ដូចជាយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ៕**

**រដ្ឋមន្ត្រី**

**បណ្ឌិត អ៊ុក រ៉ាប៊ុន**